**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករបរធនបាលកិច្ច**

លេខៈ ០០១/២១.... និ.ប.ធ./ប្រ.ក.

# សេចក្តីប្រកាសព័ត៌មាន

**និយ័តករបរធនបាលកិច្ច (និ.ប.ធ)** មានកិត្តិយសសូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតស្នេហាជាតិដ៏ជ្រាលជ្រៅរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់ដែលមានការពាក់ព័ន្ធ ដើម្បីកំណត់ឱ្យប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែជាឥស្សរជនដែលមាន "**សញ្ជាតិខ្មែរតែមួយគត់**" ដែលនេះជាការធានា ទាំងផ្លូវច្បាប់ ទាំងផ្លូវនយោបាយ ឱ្យឥស្សរជនជាន់ខ្ពស់ដែលកាន់មុខដំណែងជាមេដឹកនាំនៃស្ថាប័នកំពូលទាំង ៤ របស់ជាតិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ចំពោះជាតិ ប្រជាជន និងមាតុភូមិកម្ពុជា, ធ្វើការដឹកនាំប្រទេសដោយផ្តល់ឧត្តមប្រយោជន៍ជាតិជាធំ ក៏ដូចជាប្រឆាំងទៅនឹងការជ្រៀតជ្រែកពីខាងក្រៅ ចូលមកក្នុងកិច្ចការផ្ទៃក្នុងនៃការដឹកនាំជាតិរបស់កម្ពុជា។

ថ្ងៃព្រហស្បតិ៍ ១កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២១

អាសយដ្ឋានៈ អគារ១៦៨F (ជាន់ទី៨) ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia